**ធនាគារជាតិ នៃ កម្ពុជា**

លេខ..........................................................

# សុន្ទរកថា
# ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៦
# និងទិសដៅការងារឆ្នាំ២០១៧ របស់ធនាគារជាតិនៃកម្ពុជា
## ធនាគារជាតិនៃកម្ពុជា ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៧

**សូមគោរព៖**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអនេកប្បការ ដែលបានចូលរួមក្នុងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧ របស់ធនាគារជាតិនៃកម្ពុជា។ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ដែលមានវត្តមាននៅក្នុងសន្និបាតនាពេលនេះ។ សន្និបាតរបស់យើងត្រូវបានធ្វើឡើងក្នុងគោលបំណងអបអរសាទរ និងផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយអំពីលទ្ធផលដែលធនាគារជាតិនៃកម្ពុជាទទួលបាននៅឆ្នាំ២០១៦កន្លងមកនេះ ព្រមទាំងទស្សនវិស័យនិងទិសដៅការងារឆ្នាំ២០១៧ ក្នុងការឈានទៅសម្រេចឱ្យបានជោគជ័យថ្មីៗបន្ថែមទៀត។ លើសពីនេះ ការរៀបចំសន្និបាតនេះឡើងក៏ដើម្បីផ្តល់ឱកាសឱ្យមន្ត្រីបុគ្គលិកទាំងស្នាក់ការកណ្តាល និងសាខារាជធានីខេត្តបានជួបជុំគ្នាក្រោមបរិយាកាសសប្បាយរីករាយ សាមគ្គីភាព និងភាតរភាព ក្នុងស្មារតីជាសមាជិកគ្រួសារតែមួយ។ សន្និបាតរបស់យើងនាពេលនេះ ក៏ត្រូវបានធ្វើឡើងបន្ទាប់ពីការប្រារព្ធពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣៨ នៃទិវា៧មករា ដែលជាថ្ងៃជ័យជម្នះជាប្រវត្តិសាស្ត្ររបស់ប្រជាជនកម្ពុជាក្នុងការផ្តួលរលំរបបប្រល័យពូជសាសន៍ ប៉ុល ពត។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

នៅឆ្នាំ២០១៦នេះ សេដ្ឋកិច្ចពិភពលោកបានបន្តដើបឡើងក្នុងល្បឿនយឺតនៅឡើយ ដោយសារកំណើនសេដ្ឋកិច្ចនៅទន់ខ្សោយក្នុងតំបន់អឺរ៉ូនិងប្រទេសជប៉ុន ការបន្ថយល្បឿនកំណើនសន្សឹមៗទៅរកតុល្យភាពរបស់សេដ្ឋកិច្ចចិន និងកំណើនយឺតជាងការរំពឹងទុកនៃ



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

សេដ្ឋកិច្ចសហរដ្ឋអាមេរិក។ ប៉ុន្តែ សេដ្ឋកិច្ចតំបន់អាស៊ី ជាពិសេសប្រទេសអាស៊ាន នៅបន្តរក្សាបានសន្ទុះកំណើនរឹងមាំធៀបនឹងតំបន់ដទៃ។

ដោយឡែក សេដ្ឋកិច្ចកម្ពុជាបន្តមានកំណើនគួរជាទីពេញចិត្ត ក្នុងអត្រាខ្ពស់ប្រមាណ ៧% ដែលគាំទ្រដោយកំណើនរឹងមាំនៃការនាំចេញផលិតផលសម្លៀកបំពាក់និងស្បែកជើង កំណើនក្នុងវិស័យសំណង់និងអចលនទ្រព្យ និងវិស័យទេសចរណ៍ ស្របពេលដែលវិស័យកសិកម្មបានកើនឡើងជាងមុនបន្តិច។ កម្ពុជាក៏រក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ ប្រកបដោយភាពរឹងមាំ ដែលធ្វើឱ្យទស្សនវិស័យសេដ្ឋកិច្ចបន្តមានភាពវិជ្ជមាននាពេលអនាគត។ សមិទ្ធផលដ៏ល្អប្រសើរនេះ ប្រសូតចេញពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការដាក់ចេញនូវគោលនយោបាយដ៏ត្រឹមត្រូវក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ និងការរួមចំណែករបស់ដៃគូអភិវឌ្ឍន៍ វិស័យឯកជននិងភាគីពាក់ព័ន្ធនានា។ គួរបញ្ជាក់ថា សមិទ្ធផលទាំងនេះ សម្រេចបានដោយសារកម្ពុជាធានាបានសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនិងភាពសុខដុមរមនារបស់ប្រជាជនក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងនាមជាធនាគារកណ្តាល ដែលដើរតួនាទីជាអាជ្ញាធររូបិយវត្ថុ និងអាជ្ញាធរត្រួតពិនិត្យនិងបញ្ញត្តិកម្មវិស័យធនាគារ ធនាគារជាតិនៃកម្ពុជាបានបន្តចូលរួមយ៉ាងសកម្មក្នុងការគាំទ្រនិងជំរុញកំណើនសេដ្ឋកិច្ចនិងកាត់បន្ថយភាពក្រីក្រ តាមរយៈការរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងអភិវឌ្ឍប្រព័ន្ធធនាគារ។ ខ្ញុំសូមជម្រាបជូននូវលទ្ធផលចម្បងៗដូចតទៅ៖

**I/- ចំពោះការរក្សាស្ថិរភាពថ្លៃ៖** អត្រាអតិផរណាបានបន្តស្ថិតក្នុងកម្រិតទាបជាមធ្យម ២,៩% នៅឆ្នាំ២០១៦នេះ ជាចម្បងដោយសារកម្រិតទាបនៃតម្លៃប្រេង និងការអនុវត្តគោលនយោបាយសារពើពន្ធ រូបិយវត្ថុនិងអត្រាប្តូរប្រាក់ សមស្របទៅនឹងកំណើនសកម្មភាពសេដ្ឋកិច្ច។ តម្លៃប្រាក់រៀលមានស្ថិរភាពល្អប្រសើរ ដោយអត្រាប្តូរប្រាក់មានកម្រិតជាមធ្យម ៤.០៥០ រៀលក្នុងមួយដុល្លារអាមេរិក ជាមួយនឹងការប្រែប្រួលនៅក្នុងខែនីមួយៗក្នុងគម្លាតតូចជាង ១% ប៉ុណ្ណោះ។ គួររំលេចថា តម្រូវការប្រាក់រៀលបានកើនឡើងជាលំដាប់ ហើយត្រូវបានបំពេញដោយការផ្គត់ផ្គង់ក្នុងកម្រិតសមស្រប ដែលជាលទ្ធផលធ្វើឱ្យអត្រាប្តូរប្រាក់មានស្ថិរភាពល្អប្រសើរ។ ការបន្តកើនឡើងតម្រូវការនេះឆ្លុះបញ្ចាំងពីកំណើនជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀល ដែលជាផ្លែផ្កាទទួលបានពីការអនុវត្តគោលនយោបាយលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនាពេលកន្លងមក។ ម្យ៉ាងទៀត ឧបករណ៍និងទីផ្សារអន្តរ

ធនាគារនិងរូបិយវត្ថុ ដែលជាមូលដ្ឋាននៃការអនុវត្តគោលនយោបាយរូបិយវត្ថុផ្អែកលើយន្តការទីផ្សារក៏ត្រូវបានអភិវឌ្ឍជាបន្តបន្ទាប់ ជាពិសេស ការដាក់ឱ្យដំណើរការប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO)។ ប្រតិបត្តិការថ្មីនេះបានដំណើរការប្រកបដោយភាពជោគជ័យ ដោយបានផ្តល់នូវសន្ទនីយភាពជាប្រាក់រៀលដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានតម្រូវការប្រាក់រៀលក្នុងប្រតិបត្តិការ ជាពិសេសដើម្បីយកទៅប្រើប្រាស់សម្រាប់ការផ្តល់កម្ចីដល់វិស័យកសិកម្ម និងប្រជាជននៅតាមជនបទ។ អត្រាការប្រាក់នៃប្រតិបត្តិការនេះ ក៏ត្រូវបានគ្រឹះស្ថានមួយចំនួនចាប់ផ្តើមយកធ្វើជាមូលដ្ឋាន សម្រាប់ការខ្ចីជាប្រាក់រៀលបណ្តើរៗផងដែរ។ នាពេលខាងមុខ ការអភិវឌ្ឍប្រតិបត្តិការនេះនឹងអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជាអាចកំណត់បានអត្រាការប្រាក់គោលមួយដែលមានឥទ្ធិពលដល់អត្រាការប្រាក់ទីផ្សារ។

ការរួមចំណែករក្សាស្ថិរភាពថ្លៃ និងអត្រាប្តូរប្រាក់មានសារៈសំខាន់ណាស់ចំពោះស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបង្កើនភាពច្បាស់លាស់របស់សេដ្ឋកិច្ចជាតិ ទាក់ទាញការវិនិយោគ បង្កើនការប្រើប្រាស់ និងបង្កបរិយាកាសអំណោយផលដល់ការរីកចម្រើនសកម្មភាពសេដ្ឋកិច្ច។

**II/- ចំពោះការគ្រប់គ្រងទុនបម្រុងអន្តរជាតិ៖** លំហូរចូលវិនិយោគផ្ទាល់បរទេស គួបផ្សំនឹងភាពប្រសើរនៃឱនភាពជញ្ជីងពាណិជ្ជកម្ម បានធ្វើឱ្យជញ្ជីងទូទាត់កម្ពុជាទទួលបានអតិរេក ដែលរួមចំណែកគរពូនទុនបម្រុងអន្តរជាតិឱ្យកើនឡើងជាលំដាប់។ ធនាគារជាតិនៃកម្ពុជាបានគ្រប់គ្រងទុនបម្រុងអន្តរជាតិប្រកបដោយប្រសិទ្ធភាព ដើម្បីធានាបាននូវការគរពូនទ្រព្យសម្បត្តិជាតិ ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការបម្រើដល់ការអនុវត្តគោលនយោបាយរូបិយវត្ថុ ក៏ដូចជាគោលនយោបាយអត្រាប្តូរប្រាក់ ការពង្រឹងភាពជឿទុកចិត្តរបស់វិនិយោគិន និងកិត្តិនាមរបស់កម្ពុជាលើឆាកអន្តរជាតិ។ គិតត្រឹមចុងឆ្នាំ២០១៦ ទុនបម្រុងអន្តរជាតិបានកើនដល់ ៦,៩ ប៊ីលានដុល្លារអាមេរិក ដែលអាចធានាដល់ការទូទាត់ការនាំចូលទំនិញនិងសេវាបានប្រមាណ ៥ខែ។

**III/- ចំពោះវឌ្ឍនភាពក្នុងវិស័យធនាគារ៖** វិស័យធនាគារកម្ពុជាបានបន្តរីកចម្រើនប្រកបដោយភាពរឹងមាំ មានលក្ខណៈប្រកួតប្រជែង និងបរិយាប័ន្ន។ តាមរយៈតួនាទីអន្តរ-ការិយកម្មហិរញ្ញវត្ថុ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានកេណ្ឌប្រមូលប្រភពធនធានទាំងក្នុងស្រុកនិងក្រៅស្រុក ដើម្បីយកទៅផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគចម្បងៗ ជាពិសេសវិស័យផលិតកម្ម។ នៅឆ្នាំ២០១៦នេះ ប្រាក់បញ្ញើបានកើនដល់ ៦៩% នៃផ.ស.ស ហើយឥណទានទៅកាន់វិស័យឯកជនបានកើនដល់ ៧១% នៃផ.ស.ស ពោលគឺមានកំណើន ១៨% និង

២២% រៀងគ្នាធៀបនឹងឆ្នាំ២០១៥។ កំណើនអន្តរការិយកម្មហិរញ្ញវត្ថុនេះបានរួមចំណែកគាំទ្រកំណើនសកម្មភាពសេដ្ឋកិច្ចនិងកាត់បន្ថយភាពក្រីក្រ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ គួរបញ្ជាក់ថា យោងតាមរបាយការណ៍ Doing Business 2017 របស់ធនាគារពិភពលោក ដែលបានចេញផ្សាយនៅចុងឆ្នាំ២០១៦នេះ ប្រទេសកម្ពុជាទទួលបានចំណាត់ថ្នាក់លេខ៧ទូទាំងពិភពលោក ចំពោះ "ភាពងាយស្រួលក្នុងការទទួលបានឥណទាន"។

លើសពីនេះ ទាក់ទងនឹងការរីកចម្រើននៅក្នុងវិស័យធនាគារ ខ្ញុំសូមលើកយកនូវបញ្ហាគួរឱ្យកត់សម្គាល់បី ដូចខាងក្រោម៖

**ទី១- កំណើនឥណទាន៖** កន្លងមក មានការលើកឡើងជាច្រើនពាក់ព័ន្ធនឹងកំណើនឥណទានខ្ពស់ ហើយថែមទាំងមានស្ថាប័នជាតិនិងអន្តរជាតិមួយចំនួនបានសម្តែងការព្រួយបារម្ភអំពីហានិភ័យដែលភ្ជាប់ជាមួយនឹងកំណើនឥណទាននេះ។ ជាការពិត ក្នុងរយៈពេលប្រមាណជាងមួយទសវត្សរ៍កន្លងមកនេះ ឥណទានចំពោះវិស័យឯកជនបានកើនឡើងក្នុងអត្រាខ្ពស់ បើធៀបទៅនឹងប្រទេសក្នុងតំបន់។ ប៉ុន្តែល្បឿនកំណើនឥណទានក៏មាននិន្នាការថយចុះជាលំដាប់ផងដែរ។ ផ្អែកលើការវិភាគអន្តរជាតិជាច្រើនបង្ហាញថា កំណើនឥណទានខ្ពស់មានហានិភ័យ នៅពេលដែល i/- ឥណទានត្រូវបានគរពូនទៅក្នុងវិស័យមិនមែនផលិតកម្ម ii/- គុណភាពនៃឥណទានធ្លាក់ចុះ និង iii/- ការផ្តល់ឥណទានដោយផ្អែកលើប្រភពមូលនិធិមិនមានស្ថិរភាព។ នៅកម្ពុជា កំណើនឥណទានមិនមានភាពប្រមូលផ្តុំទេ ដោយបានបែងចែកទៅកាន់វិស័យនានារបស់សេដ្ឋកិច្ច, ភាគច្រើននៃប្រភពទុនមានស្ថិរភាព, ហើយសំពៀតឥណទានមានគុណភាពល្អ ដែលឆ្លុះបញ្ចាំងតាមរយៈកម្រិតទាបនៃឥណទានមិនដំណើរការ។ កំណើនឥណទាននៅកម្ពុជាជាចម្បងបណ្តាលមកពីមូលដ្ឋានឥណទានស្ថិតនៅកម្រិតទាប ចំណូលប្រជាជននិងចំនួនប្រជាជនដែលអាចទទួលបានសេវាហិរញ្ញវត្ថុកើនឡើងយ៉ាងឆាប់រហ័ស ក្នុងស្ថានភាពដែលទីផ្សារហិរញ្ញវត្ថុប្រមូលផ្តុំលើវិស័យធនាគារនិងមិនមានឧបករណ៍ហិរញ្ញវត្ថុសម្បូរបែបនៅឡើយ។ ដូច្នេះ ប្រជាពលរដ្ឋមាននិន្នាការប្រើប្រាស់សេវាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុកើនឡើង ដើម្បីបំពេញសេចក្តីត្រូវការហិរញ្ញប្បទានក្នុងការពង្រីកការវិនិយោគនិងអាជីវកម្ម និងសកម្មភាពសេដ្ឋកិច្ចនានា រាប់បញ្ចូលទាំងតម្រូវការហិរញ្ញប្បទានរបស់ប្រជាជនពេញវ័យសម្រាប់ការទិញលំនៅដ្ឋានផងដែរ។

**ទី២- អត្រាការប្រាក់៖** អត្រាការប្រាក់ក្នុងវិស័យធនាគារនៅមានកម្រិតខ្ពស់នៅឡើយ ជាពិសេសចំពោះសេវាមីក្រូហិរញ្ញវត្ថុ។ កត្តានេះគឺដោយសារតែគ្រឹះស្ថានហិរញ្ញវត្ថុនៅកម្ពុជាភាគច្រើនទទួលហិរញ្ញប្បទានពីវិនិយោគិនក្នុងនិងក្រៅប្រទេសដែលមានអត្រាការប្រាក់ខ្ពស់

គួបផ្សំនឹងចំណាយប្រតិបត្តិការខ្ពស់ ជាពិសេសចំពោះឥណទានខ្នាតតូចនិងប្រតិបត្តិការឥណទាននៅជនបទ។ សំខាន់ជាងនេះ ធនាគារជាតិនៃកម្ពុជានៅមិនទាន់អាចកំណត់អត្រាការប្រាក់គោលដែលមានឥទ្ធិពលលើអត្រាការប្រាក់ទីផ្សារបាន ដោយសារកម្រិតដុល្លារូប-នីយកម្មខ្ពស់។ ទោះយ៉ាងណា អត្រាការប្រាក់មាននិន្នាការថយចុះជាលំដាប់។ នារយៈពេលកន្លងមក ដើម្បីរួមចំណែកកាត់បន្ថយអត្រាការប្រាក់ឥណទាន ធនាគារជាតិនៃកម្ពុជាបានបន្តធានានូវបរិស្ថានប្រកួតប្រជែងប្រកបដោយតម្លាភាពនិងសមភាព ព្រមទាំងបានលើកទឹកចិត្តដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឱ្យស្វែងរកលទ្ធភាពបន្ធូរបន្ថយអត្រាការប្រាក់ជាបន្តបន្ទាប់។ នៅឆ្នាំ២០១៦នេះ ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) បានចាប់ផ្តើមផ្តល់លទ្ធភាពឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលមានតម្រូវការប្រាក់រៀលក្នុងប្រតិបត្តិការទទួលបានសន្ទនីយភាពជាប្រាក់រៀលក្នុងអត្រាការប្រាក់ទាបសមរម្យ។

យ៉ាងណាមិញ កិច្ចខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជាក្នុងការបន្ធូរបន្ថយអត្រាការប្រាក់ ក៏ទាមទារឱ្យមានការចូលរួមចំណែកពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុផងដែរ ដូចជាការផ្តល់សេវានិងផលិតផលដែលសមស្របទៅតាមតម្រូវការ និងលទ្ធភាពសងរបស់អតិថិជន។ នាពេលថ្មីៗនេះ ការដាក់ឱ្យអនុវត្តនូវអនុស្សរណៈយោគយល់ស្តីពីសេចក្តីណែនាំការផ្តល់ឥណទាន បានសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់សមាគមមីក្រូហិរញ្ញវត្ថុក្នុងការបញ្ចៀសបំណុលវ័ណ្ឌករបស់អតិថិជន កាត់បន្ថយហានិភ័យឥណទាន និងរួមចំណែកកាត់បន្ថយអត្រាការប្រាក់ឥណទាន តាមរយៈការពង្រឹងគុណភាព និងភាពពេញលេញនៃការផ្តល់ព័ត៌មានឥណទានដល់ក្រុមហ៊ុនក្រេឌីតប្យូរ៉ូកម្ពុជា, ការសិក្សាកាន់តែល្អិតល្អន់លើលទ្ធភាពសងប្រាក់របស់អតិថិជន, ការលើកកម្ពស់ការប្រកួតប្រជែងប្រកបដោយវិជ្ជាជីវៈនិងក្រមសីលធម៌, និងការជំរុញការអនុវត្តគោលការណ៍គាំពារអតិថិជន។

**ទី៣- ការលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ៖** វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាត្រូវបានទទួលស្គាល់ពីមជ្ឈដ្ឋានជាតិនិងអន្តរជាតិថា បានលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុនិងរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជាជាលំដាប់។ ក្នុងឆ្នាំ២០១៦នេះ ធនាគារជាតិនៃកម្ពុជាបានរៀបចំសន្និសីទថ្នាក់ជាតិ ស្តីពីការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ សន្និសីទនេះត្រូវបានរៀបចំឡើង ដើម្បីអបអរសាទរការរីកចម្រើននៃវិស័យមីក្រូហិរញ្ញវត្ថុក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ ក៏ដូចជាដើម្បីលើកកម្ពស់ការ

យល់ដឹងរបស់សាធារណជនអំពីការអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា និងតួនាទីដ៏សំខាន់របស់វិស័យនេះក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

ដើម្បីលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុឱ្យបានទូលំទូលាយ និងកាត់បន្ថយចំណាយប្រតិបត្តិការ ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ដែលអាចធ្វើឱ្យការផ្តល់សេវាកាន់តែមានប្រសិទ្ធភាពនិងចំណាយទាប។ ក្នុងទិសដៅនេះ ប្រព័ន្ធសម្រាប់សេវាទូទាត់រហ័ស (Fast Payment) ត្រូវបានដាក់ឱ្យប្រើប្រាស់ ដែលមិនត្រឹមតែជួយជំរុញការប្រើប្រាស់ប្រាក់រៀលប៉ុណ្ណោះទេ តែថែមទាំងផ្តល់លទ្ធភាពឱ្យប្រជាពលរដ្ឋអាចផ្ទេរប្រាក់ពីគណនីធនាគារមួយ ទៅគណនីធនាគារអ្នកទទួលមួយទៀតបានភ្លាមៗ។ នៅឆ្នាំ២០១៧នេះ ធនាគារជាតិនៃកម្ពុជានឹងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ Central Shared Switch ដែលនឹងផ្តល់លទ្ធភាពឱ្យអតិថិជន ធនាគារអាចប្រើប័ណ្ណឥណពន្ធ ដកប្រាក់ និងទូទាត់តាមទីផ្សារ ទោះជាម៉ាស៊ីននោះមិនមែនជាម៉ាស៊ីនរបស់គ្រឹះស្ថានធនាគារខ្លួនក៏ដោយ។ លើសពីនេះ ការទូទាត់តាមរយៈទូរស័ព្ទ និងទិញទំនិញអនឡាញ នឹងអាចធ្វើឡើងដោយងាយស្រួល មានសុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់។

ម្យ៉ាងទៀត ធនាគារជាតិនៃកម្ពុជាបានលើកកម្ពស់ចំណេះដឹងហិរញ្ញវត្ថុ តាមរយៈការធ្វើយុទ្ធនាការ "តោះ!និយាយពីលុយ" ឱ្យកាន់តែទូលំទូលាយ ជាពិសេស ដល់សិស្សានុសិស្សថ្នាក់បឋមសិក្សានិងវិទ្យាល័យ សំដៅធានានិរន្តរភាពនៃកំណើនបរិយាប័ន្នហិរញ្ញវត្ថុ។ យុទ្ធនាការនេះមានគោលបំណងអប់រំប្រជាជន ឱ្យយល់កាន់តែច្បាស់អំពីការគ្រប់គ្រងហិរញ្ញវត្ថុគ្រួសារ ការខ្ចី និងការឱ្យខ្ចី ប្រកបដោយភាពទទួលខុសត្រូវ និងយល់ដឹងអំពីលក្ខណៈនៃការខ្ចី ដើម្បីធានានិរន្តរភាពនៃបរិយាប័ន្នហិរញ្ញវត្ថុ។

**IV- ចំពោះការរក្សាស្ថិរភាពហិរញ្ញវត្ថុ៖** តាមរយៈការត្រួតពិនិត្យទាំងកម្រិតមីក្រូនិងម៉ាក្រូ និងការតាមដានហានិភ័យនានាជាប្រចាំ ស្ថិរភាពវិស័យធនាគារបន្តរក្សាបានយ៉ាងរឹងមាំ ដែលបានរួមចំណែកជាចម្បងដល់ស្ថិរភាពហិរញ្ញវត្ថុទាំងមូល ដោយសារភាពគ្របដណ្តប់នៃវិស័យធនាគារក្នុងវិស័យហិរញ្ញវត្ថុ។ នៅឆ្នាំ២០១៦នេះ ធនាគារជាតិនៃកម្ពុជាបានពង្រឹងបទប្បញ្ញត្តិលើអនុបាតគ្របខ័ណ្ឌសន្ទនីយភាព (LCR) ស្របតាមគោលការណ៍គ្រឹះបាសែល III និងការបង្កើនដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ បន្ថែមលើវិធានការដែលមានស្រាប់។ វិធានការទាំងនេះ គួបផ្សំនឹងស្ថានភាពទីផ្សារនិងការប្រុងប្រយ័ត្នរបស់គ្រឹះស្ថាន បាននាំឱ្យកំណើនឥណទានថយចុះ ហើយរំពឹងថានឹងបន្តថមថយនាពេលខាងមុខ

ដែលនឹងជួយពង្រឹងស្ថិរភាពហិរញ្ញវត្ថុឱ្យកាន់តែរឹងមាំ។ បន្ថែមលើនេះ វិធានការម៉ាក្រូប្រុងប្រយ័ត្នមួយចំនួនទៀតក៏កំពុងត្រូវបានសិក្សា និងគ្រោងដាក់ឱ្យអនុវត្តនាឆ្នាំ២០១៧នេះ។

**V- ចំពោះការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម៖** សមត្ថភាពតាមដាននិងវាយតម្លៃប្រតិបត្តិការហិរញ្ញវត្ថុត្រូវបានបន្តលើកកម្ពស់ជាប់ជាប្រចាំ និងបានពង្រឹងការទប់ស្កាត់ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មបានយ៉ាងមានប្រសិទ្ធភាព។ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានសម្រេចដោយជោគជ័យនូវការវាយតម្លៃហានិភ័យថ្នាក់ជាតិ ដែលលទ្ធផលត្រូវបានទទួលស្គាល់ដោយក្រុមអ្នកវាយតម្លៃ APG ហើយក៏បានសហការជាមួយក្រុមអ្នកវាយតម្លៃ APG ក្នុងការទទួលការចុះវាយតម្លៃអញ្ញមញ្ញលើក្របខ័ណ្ឌច្បាប់និងប្រសិទ្ធភាពនៃការអនុវត្តក្នុងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ជាស្ថាពរ។

**VI- ចំពោះការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ៖** ធនាគារជាតិនៃកម្ពុជានឹងបន្តរួមចំណែកក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់និងពិភពលោក ជាពិសេសលើ i/- ការលើកកម្ពស់តួនាទីរបស់អាស៊ានឱ្យក្លាយជាប៉ូលពាណិជ្ជកម្មដ៏លេចធ្លោមួយ សំដៅពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចជាមួយមហាអំណាចសេដ្ឋកិច្ចនានាក្នុងពិភពលោក តាមរយៈកិច្ចសហប្រតិបត្តិការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ាន ii/- ការពង្រឹងបណ្តាញសុវត្ថិភាពហិរញ្ញវត្ថុក្នុងតំបន់ ក្រោមពហុភាវូបនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (CMIM) របស់អាស៊ាន+៣ និង iii/- ការផ្លាស់ប្តូរបទពិសោធន៍និងព័ត៌មានក្នុងក្របខ័ណ្ឌទ្វេភាគីនិងពហុភាគី។

**VII- ចំពោះការពង្រឹងអភិបាលកិច្ចនិងធនធានមនុស្ស៖** ការគ្រប់គ្រងផ្ទៃក្នុងត្រូវបានពង្រឹង ហើយសមត្ថភាពធនធានមនុស្សលើផ្នែកឯកទេសកម្មចំណេះដឹងបច្ចេកទេស ត្រូវបានអភិវឌ្ឍជាលំដាប់ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពការងាររបស់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា។ ជាក់ស្តែង ឆ្លើយតបនឹងការប្រែប្រួលនៃនិម្មាបនកម្មហិរញ្ញវត្ថុនិងស្តង់ដារអន្តរជាតិទាក់ទងនឹងការត្រួតពិនិត្យធនាគារ ធនាគារជាតិនៃកម្ពុជាបានបង្កើនការបណ្តុះបណ្តាលមន្ត្រីបុគ្គលិកតាមប្រព័ន្ធ Online ក្រោមកម្មវិធី FSI Connect របស់វិទ្យាស្ថានស្ថិរភាពហិរញ្ញវត្ថុនៃធនាគារសម្រាប់ការទូទាត់អន្តរជាតិ។ លើសពីនេះ ចំនួនមន្ត្រីដែលទទួលបានសញ្ញាបត្រជំនាញទទួលស្គាល់ជាអន្តរជាតិបានកើនឡើងជាលំដាប់ ជាពិសេសពាក់ព័ន្ធនឹងជំនាញគណនេយ្យ (សញ្ញាបត្រ CPA) និងជំនាញវិភាគហិរញ្ញវត្ថុ (សញ្ញាបត្រ CFA) ស្របពេលដែលមន្ត្រីបុគ្គលិកត្រូវបានបញ្ជូនឱ្យទៅសិក្សាថ្នាក់បរិញ្ញាបត្រ អនុបណ្ឌិត និងបណ្ឌិត នៅប្រទេសអភិវឌ្ឍន៍កាន់តែច្រើនឡើង។ នាឆ្នាំ២០១៧នេះ ធនាគារជាតិនៃកម្ពុជាគ្រោងនឹង

បង្កើតឱ្យមានឋានៈសេដ្ឋវិទូនិងសេដ្ឋវិទូជាន់ខ្ពស់ ក្នុងគោលដៅពង្រឹងឯកទេសកម្មជំនាញផ្នែកសេដ្ឋកិច្ចបន្ថែមទៀត។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ចំពោះទស្សនវិស័យឆ្នាំ២០១៧ កំណើនសេដ្ឋកិច្ចពិភពលោកត្រូវបានព្យាករថានឹងមានអត្រា ៣,៥% ពោលគឺខ្ពស់ជាងឆ្នាំ២០១៦។ ដោយកម្ពុជាមានភាពបើកទូលាយ និងសមាហរណកម្មខ្ពស់ទៅក្នុងតំបន់និងពិភពលោក សេដ្ឋកិច្ចកម្ពុជានឹងអាចទទួលបានភាពអំណោយផលពីការកើនឡើងនៃកំណើនសេដ្ឋកិច្ចពិភពលោកដែរ។ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗ ក៏ដូចជារាជរដ្ឋាភិបាលបានព្យាករថា សេដ្ឋកិច្ចកម្ពុជានឹងបន្តស្ថិតលើគន្លងនៃកំណើនរយៈពេលវែង ក្នុងអត្រាខ្ពស់ប្រមាណ ៧% នៅឆ្នាំ២០១៧ ដោយសារភាពរឹងមាំនៃវិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើង កំណើនក្នុងវិស័យសំណង់និងអចលនទ្រព្យ ជាមួយនឹងការកើនឡើងនៃវិស័យទេសចរណ៍និងកសិកម្ម។ ចំពោះអត្រាអតិផរណា ត្រូវបានប៉ាន់ស្មានថានឹងកើនឡើងបន្តិចធៀបនឹងឆ្នាំ២០១៦ ដោយសារនិន្នាការកំណើនថ្លៃប្រេងនិងអតិផរណានាំចូលពីប្រទេសជិតខាង ខណៈដែលអត្រាប្តូរប្រាក់នឹងបន្តមានស្ថិរភាពល្អប្រសើរក្នុងរង្វង់ ៤.០៥០ រៀលក្នុងមួយដុល្លារអាមេរិក។

ទោះជាយ៉ាងនេះក្តី សក្តានុពលនៃកំណើនសេដ្ឋកិច្ចខាងលើក៏ប្រឈមនឹងហានិភ័យនៃការថមថយផងដែរ ដូចជា៖ i/- ផលប៉ះពាល់អវិជ្ជមានពីនិន្នាការឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិកចំពោះការនាំចេញនិងវិស័យទេសចរណ៍របស់កម្ពុជា ដែលមានសេដ្ឋកិច្ចដុល្លារូបនីយ-កម្មខ្ពស់ ii/- ភាពរឹតត្បិតនៃស្ថានភាពហិរញ្ញវត្ថុអន្តរជាតិដែលអាចកាត់បន្ថយលំហូរមូលធនចូលក្នុងតំបន់ នឹងអាចមានឥទ្ធិពលបន្តមកលើកម្ពុជា តាមរយៈការបន្ថយលំហូរវិនិយោគនិងដាក់សម្ពាធលើការបង្កើនអត្រាការប្រាក់នៅកម្ពុជា បន្ទាប់ពីគណៈកម្មាធិការទីផ្សារចំហរបស់ធនាគារកណ្តាលអាមេរិក បានសម្រេចដំឡើងអត្រាការប្រាក់គោលនាខែធ្នូ ឆ្នាំ២០១៦កន្លងទៅ iii/- ការកើនឡើងភាពប្រកួតប្រជែងនៅលើទីផ្សារនាំចេញជាមួយប្រទេសក្នុងតំបន់ និង iv/- និន្នាការកើនឡើងនៃការអនុវត្តគោលនយោបាយពាណិជ្ជកម្មគាំពារនិយមនៅប្រទេសអភិវឌ្ឍន៍ ដែលអាចដាក់សម្ពាធលើការនាំចេញរបស់កម្ពុជា។ ចំពោះហានិភ័យខាងក្នុងសេដ្ឋកិច្ចកម្ពុជាអាចប្រឈមនឹងហានិភ័យនៃការថយចុះល្បឿនកំណើនក្នុងវិស័យសំណង់ និងអចលនទ្រព្យ កំណើនឥណទានយ៉ាងឆាប់រហ័សទៅវិស័យនេះ និងការថយចុះនៃឧត្តមភាពប្រកួតប្រជែងផ្នែកថ្លៃ ដោយសារកំណើនប្រាក់បៀវត្សនិយោជិត។ ទន្ទឹមនេះ កម្ពុជាក៏នៅបន្តមានបញ្ហាប្រឈមរចនាសម្ព័ន្ធចម្បងៗមួយចំនួនផងដែរ រួមមាន៖ កម្រិតដុល្លារូបនីយកម្មខ្ពស់,

តម្លៃខ្ពស់នៃថាមពលនិងដឹកជញ្ជូន, កង្វះខាតផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងកង្វះធនធានមនុស្សមានជំនាញ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ដើម្បីជ្រាបពីសមិទ្ធផលលម្អិតដែលធនាគារជាតិនៃកម្ពុជាសម្រេចបាន និងទិសដៅការងារសំខាន់ៗ ខ្ញុំសូមអង្គសន្និបាតមេត្តាត្រងត្រាប់ស្តាប់បទឧទ្ទេសនាមរបស់ថ្នាក់ដឹកនាំយើង ដែលនឹងរាយការណ៍ជូនអង្គសន្និបាតនាពេលបន្តិចទៀតនេះ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណជាភិយ្យោភាព ចំពោះក្រុមប្រឹក្សាភិបាល និងមន្ត្រីបុគ្គលិកគ្រប់ជាន់ថ្នាក់របស់ធនាគារជាតិនៃកម្ពុជា ដែលបានខិតខំប្រឹងប្រែងក្នុងការបំពេញមុខងារ-ភារកិច្ច ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីសម្រេចបានសមិទ្ធផលដ៏ប្រសើរជាបន្តបន្ទាប់នារយៈពេលកន្លងមក។ ខ្ញុំក៏សូមថ្លែងអំណរគុណជាអនេកចំពោះគ្រប់ក្រសួង-ស្ថាប័ននានា នៅក្នុងវិស័យសាធារណៈនិងឯកជន ព្រមទាំងដៃគូអភិវឌ្ឍន៍ទាំងអស់ដែលបានគាំទ្រនិងរួមចំណែកនៅក្នុងសមិទ្ធផលនេះ។

ជាបរិយោសាន ខ្ញុំសូមជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និង នាងកញ្ញា ឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ ខ្ញុំសូមឱ្យអង្គសន្និបាតរបស់យើងប្រព្រឹត្តទៅប្រកបដោយជោគជ័យ និងផ្លែផ្កា។

**ខ្ញុំសូមប្រកាសបើកអង្គសន្និបាតជាផ្លូវការចាប់ពីពេលនេះតទៅ។**

**សូមអរគុណ**!